

ប្រទេសកម្ពុជា

# បច្ចុប្បន្នភាពទីផ្សារ និងការតាមដានរដូវកាល

ខែកញ្ញា ឆ្នាំ២០២២

ផ្តោតលើ៖ ឥទ្ធិពលនៃវិបត្តិស្បៀងអាហារ និងប្រេងឥន្ធនៈសកលលោក លើតម្លៃស្បៀងអាហារ និងដំណើរការរបស់ផ្សារ

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

WFP

USDA

USAID
ជំនួយពីពលរដ្ឋអាមេរិក

# បុព្វកថា

**អំឡុងពេលជាង៧ខែនៃជម្លោះអ៊ុយក្រែន** សង្គ្រាម និងការដាក់ទណ្ឌកម្មលើរុស្ស៊ីកំពុងធ្វើឲ្យប៉ះពាល់ខ្លាំងដល់ទីផ្សារថាមពល និងស្បៀងអាហារ ដោយសារប្រទេសទាំងពីរជាអ្នកនាំចេញគ្រាប់ធញ្ញជាតិសំខាន់ (ជាពិសេសស្រូវសាឡី និងស្រូវបាឡេ) ជីកសិកម្ម (ដូចជាប៉ូតាស្យូម អាសូត ផូស្វ័រ)។ រុស្ស៊ី គឺជាប្រទេសដែលផលិត និងនាំចេញប្រេងឆៅ និងឧស្ម័នធម្មជាតិដ៏ធំរបស់ពិភពលោក។

**<u>តម្លៃស្រូវសាឡី ពោត និងអង្ករ បានហក់ឡើងម្តងទៀតក្នុងខែកញ្ញា</u>។** ជម្លោះនៅអ៊ុយក្រែនបានផ្លាស់ប្តូរគំរូពាណិជ្ជកម្ម ផលិតកម្ម និងការប្រើប្រាស់ជាសកល ឲ្យទៅជាឥទ្ធិពល ដែល<u>តម្លៃនឹងស្ថិតក្នុងកម្រិតខ្ពស់ជាប្រវត្តិសាស្ត្រ រហូតដល់ចុងឆ្នាំ២០២៤</u> ដែលធ្វើឲ្យអសន្តិសុខស្បៀង និងអតិផរណាស្បៀងអាហារកាន់តែធ្ងន់ធ្ងរ។

**លទ្ធភាពទទួលបានជីកសិកម្មនឹងក្លាយជាបញ្ហាប្រឈមចម្បងនៅប៉ុន្មានខែខាងមុខ** ដោយសារជីសកលនៅតែមានតម្លៃខ្ពស់។ នេះទំនងជាមាន<u>ឥទ្ធិពលខ្លាំង</u>ដល់ផលិតកម្មស្បៀងអាហារនៅជុំវិញពិភពលោកក្នុងឆ្នាំ២០២៣។ បើទោះជាមានភាពប្រសើរឡើងខ្លះៗក្នុងខែសីហានេះប៉ុន្តែ<u>តម្លៃជីសកលនៅតែខ្ពស់ក្នុងខែកញ្ញា</u>។

**វិបត្តិស្បៀងអាហារសកលកាន់តែមានភាពធ្ងន់ធ្ងរដោយសារប្រទេសមួយចំនួនកំពុងរិតត្បិតការធ្វើពាណិជ្ជកម្មស្បៀងអាហារ** ដើម្បីបង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងកាត់បន្ថយតម្លៃ។ គិតត្រឹមថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ មានប្រទេសចំនួន១៨ បានហាមឃាត់ការនាំចេញស្បៀងអាហារចំនួន២៥ ហើយប្រទេសចំនួន៥ បានអនុវត្តការរិតត្បិតការនាំចេញចំនួន៦។ បើទោះបីជាការបើកឡើងវិញនូវផ្នែកខ្លះនៃកំពង់ផែសមុទ្រខ្មៅរបស់អ៊ុយក្រែនបានបន្ថយសម្ពាធលើទីផ្សារស្បៀងអាហារសកល ប៉ុន្តែក្តីបារម្ភថ្មីបានកើតឡើងក្នុងខែកញ្ញា ពាក់ព័ន្ធនឹងស្ថានភាពធាតុអាកាសធ្ងន់ធ្ងរ រួមមានភ្លៀងធ្លាក់ខ្លាំងក្នុងប្រទេសប៉ាគីស្ថាន និងរលកកម្តៅនៅអឺរ៉ុប <u>កំពុងព្រមានពី"ការកើនឡើងតម្លៃ"</u>។

**បញ្ហានេះមិនបានកើតឡើងដាច់ដោយឡែកនៅទេ។** កូវីដ-១៩បានប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូល និងតម្រូវការគ្រួសារ ជាហេតុធ្វើឲ្យមានឧបសគ្គដល់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល កើនឡើងអតិផរណា និងបំណុលក្នុងប្រទេសជាច្រើន - ធ្វើឲ្យរំខានដល់ការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩។ លទ្ធផលនៃការអង្កេតគ្រួសារដ៏ញឹកញាប់មួយរបស់ WFP UNICEF និង ADB ក្នុងប្រទេសកម្ពុជាចាប់តាំងពីកើតមានការរាតត្បាតជំងឺបានបង្ហាញពីការថយចុះនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ពាក់ព័ន្ធនឹងបញ្ហាប្រាក់ចំណូល និងតម្លៃទំនិញ។

**ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក កម្ពុជាជាប្រទេស<u>ប្រឈមខ្លាំងទៅនឹងការកើនឡើងតម្លៃថាមពល</u>** ដោយសារតែការនាំចូលឥន្ធនៈខ្ពស់ធៀបនឹង GDP ការប្រើប្រាស់អគ្គិសនីក្នុងស្រុកនៅមានកម្រិត និងការពឹងលើឥន្ធនៈផូស៊ីល។ ជាការពិត ការឡើងថ្លៃប្រេង គួបផ្សំនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងចិនដែលជាដៃគូពាណិជ្ជកម្មដ៏ធំរបស់កម្ពុជា <u>ជាកត្តាសំខាន់រារាំងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា</u> ដែលបានព្យាករនៅត្រឹម ៤,៥% សម្រាប់ឆ្នាំ២០២២។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ** លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀងនៅតាមផ្សារនានា ក្នុងប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក (WFP) សហការជាមួយការិយាល័យទីផ្សារកសិកម្ម (AMO) តាមដានតម្លៃលក់រាយ និងលក់ដុំរបស់ស្បៀងអាហារសំខាន់ៗ (ឧបសម្ព័ន្ធទី១ និងទី២) នៅក្នុងផ្សារចំនួន៥៦ ទាំងនៅទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលផ្នែកវិធីសាស្ត្រ)។ ជាមធ្យម ប្រធានផ្សារ និងអាជីវករចំនួន ២៥០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍។ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស់ទីផ្សារ ទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។

# មាតិកា


| | | |
|---|---|---|
| **១.** | **របកគំហើញសំខាន់ៗ** | ៣ |
| **២.** | **លទ្ធផល** | |
| | ការដំណើរការរបស់ផ្សារ៖ ទិដ្ឋភាពទូទៅ | ៤ |
| | ការទៅផ្សារ៖ទិន្នាការអតិថិជន | ៥ |
| | ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន | ៦ |
| | ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន | ៧ |
| | ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រកួន | ៨ |
| | ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា | ៩ |
| | ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ នឹងទីប្រជុំជន | ១០ |
| | ការតាមដានរដូវកាល៖ របាយទឹកភ្លៀង | ១១ |
| | ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ | ១២ |
| **៣.** | **បរិបទ** | |
| | ពាណិជ្ជកម្ម | ១៣ |
| | ការឆ្លើយតបផ្នែកនយោបាយ | ១៤ |
| **៤.** | **វិធីសាស្ត្រ និងទីតាំងផ្សារ** | ១៥ |
| **៥.** | **ឧបសម្ព័ន្ធទី១** | |
| | បម្រែបម្រួលថ្លៃលក់រាយ | ១៦ |
| **៦.** | **ឧបសម្ព័ន្ធទី២** | |
| | បម្រែបម្រួលថ្លៃលក់ដុំ | ១៧ |
| **៧.** | **ឧបសម្ព័ន្ធទី៣** | |
| | តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន | ១៨ |

## កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**GDP**

២០២១ ៣,០%

២០២២ ៤,៨%

*ADB ព្យាករអត្រាអតិផរណានៅកម្ពុជាថាកើនដល់ ៥,០% នៅឆ្នាំ២០២២។ **ក្នុងខែសីហា ឆ្នាំ២០២២ សន្ទស្សន៍តម្លៃអ្រើប្រាស់រួម (CPI)* បានថយចុះ ០,៥% ធៀបនឹងខែមុន (កើនឡើង៤,៩%ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន)។** គ្រួសារ កម្ពុជាចំណាយស្មើរតែពាក់កណ្ដាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ (៦០% សម្រាប់គ្រួសារក្រីក្រ) (CSES ២០១៩/២០)។*

**អតិផរណា**

CPI កក្កដា ២០២២ **១៩៩,៣**

CPI សីហា ២០២២ **១៩៨,៣**

**CPI ក្នុងខែកញ្ញា ឆ្នាំ២០២២ មិនទាន់មាននៅឡើយទេ កំឡុងពេលរៀបចំរបាយការណ៍*




*<u>សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO (FFPI)</u>បង្ហាញនិន្នាការថយចុះតាំងពីខែកក្កដា ឆ្នាំ២០២២ ដោយសារតម្លៃប្រេងឆាក្នុងសកលលោកបានធ្លាក់ចុះ។ ក្នុងខែកញ្ញា ឆ្នាំ២០២២ វាបានថយចុះ ១,២ ធៀបនឹងខែមុន ប៉ុន្តែ នៅខ្ពស់ជាងឆ្នាំមុនក្នុងខែដូចគ្នាប្រមាណ ៥,៥% ។ សន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា (FPI) បានថយចុះ ០,៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤,៤% ធៀបនឹងខែដដែលកាលពីឆ្នាំមុន)។*

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា




*តម្លៃលក់រាយប្រេងសាំង (ធម្មតា) បានថយចុះ ៥,០% ខណៈប្រេងម៉ាស៊ូតបានកើនឡើង២,០% ក្នុងខែកញ្ញា ឆ្នាំ២០២២ ធៀបនឹងខែមុន (ក្រសួងពាណិជ្ជកម្ម ខែកញ្ញា ឆ្នាំ២០២២)។ ប៉ុន្តែ បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុនវិញ តម្លៃប្រេងនៅតែខ្ពស់ (+១៤,០% សម្រាប់ប្រេងសាំងធម្មតានិង +៤៥,០ % សម្រាប់ប្រេងម៉ាស៊ូត) ហើយនៅតែ**មានឥទ្ធិពលអវិជ្ជមានលើផលិតកម្មស្បៀង និងការដឹកជញ្ជូន។***

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា
២០២២

# សង្ខេបរបកគំហើញសំខាន់ៗ

ក្នុងខែកញ្ញា ឆ្នាំ២០២២ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានធ្លាក់ចុះបន្តិច (-២,0% ធៀបនឹងខែមុន ប៉ុន្តែ +១,៨% ធៀបនឹងឆ្នាំមុន) ទៅ ១០៨.៩១៨ រៀល/ម្នាក់ ក្នុង១ខែ ស្មើនឹង ២៦,៦ ដុល្លារ។ ជាមធ្យម តម្លៃកញ្ចប់ស្បៀងអហារនៅទីប្រជុំជន (២៦,៩ ដុល្លារ៖ -២,២%) ខ្ពស់ជាងនៅជនបទបន្តិច (២៦,0 ដុល្លារ៖ -១,៣% ធៀបនឹងខែមុន)។

តម្លៃស្បៀងអាហារភាគច្រើនក្នុងកញ្ចប់ស្បៀងអាហារមានការប្រែប្រួលតិចតួចនៅក្នុងខែកញ្ញានេះ (±<៥,0% ធៀបនឹងខែមុន) លើកលែងតែតម្លៃត្រកួន (-៧,៨% ធៀបនឹងខែមុន)។ បើទោះជាមានភាពល្អប្រសើរខ្លះៗក៏ដោយ ក៏តម្លៃស្បៀងអាហារមួយចំនួនបង្ហាញនិន្នាការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងរយៈពេលវែង រួមមាន ត្រកួន (+២៨,៩% ធៀបឆ្នាំមុន) ប្រេងឆា (+២០,៤% ធៀបនឹងឆ្នាំមុន) ដែលភាគច្រើននាំចូល និងស៊ុតទា (+១៤,៧%ធៀបឆ្នាំមុន)។

ផ្សារមានដំណើរការល្អក្នុងខែកញ្ញានេះដោយសន្ទស្សន៍ដំណើរការរបស់ផ្សារ (MFI) បានកើនឡើងខ្ពស់បំផុត ចាប់តាំងពីដើមឆ្នាំនេះ។ កំណើននេះដោយសារតែការកើនឡើងនូវទំនិញសំខាន់ៗដែលមានបរិមាណគ្រប់គ្រាន់ និងតម្លៃដែលអាចព្យាករណ៍បាន។ ជាមួយគ្នានេះដែរ ចំនួនអតិថិជនទៅផ្សារក៏បានកើនឡើងក្នុងរយៈពេលនៃការរាយការណ៍នេះដែរដែលកំណើននេះទំនងជាដោយសារតម្រូវការប្រើប្រាស់កើនឡើងក្នុងពិធីកាន់បិណ្ឌនិងភ្ជុំបិណ្ឌ។

ទោះបីជាមានភាពល្អប្រសើរខ្លះៗក៏ដោយ ក៏តម្លៃប្រេងឥន្ធនៈ នៅកម្ពុជានៅតែមានតម្លៃខ្ពស់។ លើសពីនេះទៀត ជំនន់ទឹកភ្លៀងនៅក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា គួបផ្សំនឹងតម្លៃជីកសិកម្មបន្តកើនឡើងខ្ពស់ អាចធ្វើឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅដល់ផលិតកម្មស្បៀងអាហារក្នុងស្រុកក្នុងរយៈពេលមធ្យម ពីព្រោះកសិករមិនមានលទ្ធភាពទិញធាតុចូលកសិកម្មបានដូចមុនទៀតទេ។

# ការដំណើរការរបស់ផ្សារ

សន្ទស្សន៍ដំណើរការផ្សារ (MFI)[1] វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ ពិន្ទុ MFI នៅចន្លោះពី០ ដល់១០ ដែលពិន្ទុកាន់តែខ្ពស់បង្ហាញពីដំណើរការកាន់តែល្អ។

ដំណើរការរបស់ផ្សារបន្តប្រសើរឡើងក្នុងខែកញ្ញា ឆ្នាំ២០២២ ដល់កម្រិតខ្ពស់ជាងគេតាំងពីខែមករា ឆ្នាំ២០២២ ដោយសារតែគ្រប់សមាសធាតុផ្សារទាំងអស់មានភាពប្រសើរឡើង បើទោះជាតម្លៃទំនិញដែលអាចព្យាករបានធ្លាក់ចុះបន្តិចកាលពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២២។ មិនមានប្រធានផ្សារ/អ្នកលក់បានរាយការណ៍ពីការកើនឡើងតម្លៃផ្គត់ផ្គង់ស្បៀងនោះឡើយក្នុងខែកញ្ញានេះ។




*[1] សមាសធាតុទាំងបួន ដូចជា ភាពចម្រុះនៃទំនិញ ភាពមានស្បៀង តម្លៃស្បៀង និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សាររួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។*

# ការទៅផ្សារ៖ ទិន្នាការអតិថិជន

ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារទាំង៥៦ (ផ្សារចំនួន១១ ទើបបន្ថែមក្នុងខែកញ្ញា) ដែលបានតាមដានតម្លៃនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សាររបស់ពួកគាត់នៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែនីមួយៗ។

ចំនួនអតិថិជនបានទៅផ្សារនៅសប្តាហ៍ទី២ខែកញ្ញា ឆ្នាំ២០២២ មានភាពល្អប្រសើរឡើងគួរឲ្យកត់សម្គាល់ បន្ទាប់ពីបានធ្លាក់ចុះកាលពីសប្តាហ៍ទី១ គឺកើនឡើងដល់កម្រិតខ្ពស់បំផុតចាប់តាំងពីដើមឆ្នាំនេះមក។ កំណើននេះទំនងជាបណ្តាលមកពីតម្រូវការប្រើប្រាស់បានកើនឡើងក្នុងអំឡុងពេលប្រារព្ធពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២។




**បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ**

*[1]តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងស៊េរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

**តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB)** ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។

**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានថយចុះបន្តិចក្នុងខែកញ្ញាឆ្នាំ២០២២** (-២,០% ធៀបនឹងខែមុន ប៉ុន្តែ +១,៨% ធៀបនឹងឆ្នាំមុន) ដល់តម្លៃ ១០៨.៩១៨ រៀល/ម្នាក់/ខែ (ប្រហែល ២៦,៦ ដុល្លារ)។ **តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**មានតម្លៃខ្ពស់ជាងបន្តិចនៅទីប្រជុំជន (២៦,៩ ដុល្លារ) បើធៀបនឹងជនបទ (២៦,០ ដុល្លារ)។

២០ កុម្ភៈ ២០២១៖ ការចម្លងក្នុងសហគមន៍លើកទី២

២៤ កុម្ភៈ ២០២២៖ ចាប់ផ្ដើមសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន

១៤-១៦ មេសា៖ ចូលឆ្នាំខ្មែរ

១៤-២៨ មេសា ដល់ ៥ ឧសភា ២០២១៖ បិទខ្ទប់ភ្នំពេញ និងក្រុងតាខ្មៅ

២៨ មិថុនា ២០២២៖ រកឃើញករណីឆ្លងថ្មីកូវីដ-១៩ថ្មី បន្ទាប់ពីមិនមានការឆ្លងអស់រយៈពេល៥២ថ្ងៃ

២៩ កញ្ញា-១២ កញ្ញា ២០២១៖ បម្រាមគោលចរណ៍ទូទាំងប្រទេស និងបិទខ្ទប់ខេត្តចំនួន៨ជាប់ព្រំដែនកម្ពុជា-ថៃ

១៥ កញ្ញា ២០២១៖ បើកសាលាឡើងវិញ

២៤-២៦ កញ្ញា ២២៖ បុណ្យភ្ជុំបិណ្ឌ

៥-៧ តុលា ២០២១៖ បុណ្យភ្ជុំបិណ្ឌ

១៨-២០ វិច្ឆិកា ២០២១៖ បុណ្យអុំទូក

១៩ ធ្នូ ២០២១៖ ឆ្លងកូវីដ-១៩ អូមីក្រុង ករណីដំបូង

២០ ធ្នូ ២០២១៖ បិទបញ្ចប់ព្រឹត្តិការណ៍២០ កុម្ភៈ




## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្ដល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) មានការប្រែប្រួលទៅតាមខេត្ត និងផ្សារ។ តម្លៃខ្ពស់ជាងគេស្ថិតនៅផ្សារដងទង់ ខេត្តកោះកុង គឺ ១៣៣.២៨០ រៀល/ម្នាក់/ខែ (ប្រហែល ៣២,៥ ដុល្លារ) (ខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ២២,៤% )។ តម្លៃ BFB ទាបជាងគេស្ថិតក្នុងផ្សារស្វូង ខេត្តត្បូងឃ្មុំ គឺ ៩៣.៨២៤ រៀល/ម្នាក់/ខែ (ប្រហែល ២២,៩ ដុល្លារ) (ទាបជាងតម្លៃមធ្យមថ្នាក់ជាតិ១៣,៩%)។ ផែនទីខាងក្រោមបង្ហាញពីតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងបម្រែបម្រួលធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ។

តម្លៃកញ្ចប់លើសពីតម្លៃមធ្យមថ្នាក់ជាតិគឺភាគច្រើនមាននៅផ្សារនៅទីប្រជុំជន ដែលបង្ហាញពីបម្រែបម្រួលខ្ពស់ (ចាប់ពី៥%ឡើង) ជាងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ បើធៀបនឹងផ្សារនៅជនបទ។

### តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែកញ្ញា ឆ្នាំ២០២២)




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ | |
|---|---|---|
| | ជនបទ | ទីប្រជុំជន |
| ≥ ១០% ខ្ពស់ជាង | ០,០% | ១០០,០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ២៥,០% | ៧៥,០% |
| < ៥% ខ្ពស់ជាង | ៦០,០% | ៤០,០% |
| < ៥% ទាបជាង | ៥២,២% | ៤៧,៨% |
| ៥% ទៅ ១០% ទាបជាង | ៦០,០% | ៤០,០% |
| ≥ ១០% ទាបជាង | ២៥,០% | ៧៥,០% |

# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែកញ្ញា ឆ្នាំ២០២២ តម្លៃស៊ុតទាបានថយចុះបន្តិច (-៣,៩% ធៀបនឹងខែមុន) បន្ទាប់ពីបង្ហាញនិន្នាការកើនឡើងតាំងពីខែឧសភាដល់ខែកក្កដា ឆ្នាំ២០២២ ប៉ុន្តែ វានៅតែមានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ១៩,៧%។ តម្លៃត្រកួនបានបានថយចុះ ៧,៨% ធៀបនឹងខែមុន ប៉ុន្តែនៅតែខ្ពស់ជាងកាលពីឆ្នាំមុនក្នុងខែដូចគ្នា ២៨,៩%។ តម្លៃអង្ករចម្រុះបន្តមានស្ថេរភាព (-០,៩% ធៀបនឹងខែមុន និង ០,០% ធៀបនឹងឆ្នាំមុន)។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




[1]ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។

[2]ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្ដាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ ។

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែកញ្ញា ឆ្នាំ២០២២ តម្លៃសាច់ជ្រូក (-៣,២%) ប្រេងឆា (-២,២%) និងត្រីផ្ទក់ (+២,៦%) បង្ហាញនិន្នាថេរឬមិនប្រែប្រួល បើធៀបនឹងខែមុន។ តម្លៃប្រេងឆា ដែលភាគច្រើននាំចូលពីប្រទេសជិតខាង គឺនៅតែថ្លៃជាងខែដូចគ្នាកាលពីឆ្នាំ២០២១ ប្រមាណជា២០,៤% ក្នុងខណៈតម្លៃត្រីផ្ទក់បានថយចុះ ៥,១% និងតម្លៃសាច់ជ្រូកបានថយចុះ ៩,៦% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




*[1]ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅខែកញ្ញា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយស្បៀងអាហារសំខាន់ៗភាគច្រើន លើកលែងអង្ករចម្រុះ និងប្រេងឆា នៅទីប្រជុំជនមានតម្លៃខ្ពស់ជាងនៅជនបទ (តារាង១)។

តម្លៃមធ្យមលក់រាយអង្ករចម្រុះ ត្រីផ្ទក់ សាច់ជ្រូក ស៊ុតទា និងប្រេងឆា ទាំងនៅទីប្រជុំជន និងទីជនបទ មានបម្រែបម្រួលតិចតួច (< ៥,០%) បើធៀបនឹងខែមុន។ តម្លៃត្រកួនបានថយចុះ ២,៩% នៅជនបទ និងថយចុះ៩,៩% នៅទីប្រជុំជន បើធៀបនឹងខែមុន។ ផ្ទុយមកវិញ តម្លៃជំឡូងជ្វាបានកើនឡើង ៧,៩% នៅជនបទ និងកើនឡើង១,៩% នៅទីប្រជុំជន។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | ២.០៩៤ | ២.១០១ |
| ត្រីផ្ទក់ (រស់) (គក) | ១០.៧២០ | ១០.៤៥៧ |
| សាច់ជ្រូក (គក) | ១៩.១៨០ | ១៨.៤១៥ |
| ស៊ុតទា (១០គ្រាប់) | ៥.៩៣៦ | ៥.៧៤៧ |
| ប្រេងឆា (៥លីត្រ) | ៣២.១០៩ | ៣២.៧៣២ |
| ត្រកួន (គក) | ៣.២៥៨ | ២.៩៦៥ |
| ដំឡូងជ្វាពណ៌លឿង | ២.៦៣៩ | ២.៤៨៥ |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែសីហា ឆ្នាំ២០២២ និងខែកញ្ញា ឆ្នាំ២០២២




*សម្គាល់៖ ទិន្នន័យនេះទទួលបានពីផ្សារចំនួន៥៦។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមថ្នាក់ជាតិសរុបចាប់ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២២ មានកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំគួរឲ្យកត់សម្គាល់ (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ ស្ថានភាពសើមជាងធម្មតាបានផ្តល់លក្ខខណ្ឌអំណោយផល និងទឹកគ្រប់គ្រាន់សម្រាប់ការធ្វើកសិកម្ម។ ក្នុងខែកញ្ញា ឆ្នាំ២០២២ នៅទូទាំងប្រទេសទទួលបានបរិមាណទឹកភ្លៀងខ្ពស់ជាងធម្មតា ហើយខេត្តនៅជុំវិញបឹងទន្លេសាប និងនៅតំបន់ភាគខាងជើង ទទួលបានបរិមាណទឹកភ្លៀងច្រើនខ្លាំង (ផែនទីខាងក្រោមខាងស្តាំ)។ បរិមាណទឹកភ្លៀងច្រើនហួសប្រមាណបានបង្កឲ្យមានជំនន់ទឹកភ្លៀងនៅក្នុងតំបន់មួយចំនួនក្នុងប្រទេស។ យោងតាមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ចាប់ពីថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ទឹកជំនន់បានបង្កផលប៉ះពាល់ដល់ប្រមាណ ៨៥.៥០០ គ្រួសារ ក្នុងខេត្តចំនួន១៤។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (គិតត្រឹមខែកញ្ញា ឆ្នាំ២០២២) និងប្រតិទិនដាំដុះតាមរដូវកាល




| | | | | | | |
|---|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | ប្រមូលផល | | | | រៀបចំដី និង សាបព្រោះ |
| ស្រូវរដូវវស្សា | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | ស្ទូង / ដាំដុះ | | ប្រមូលផល |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី WFP Datavis*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែកញ្ញា ឆ្នាំ២០២២




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

# ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ

ក្នុងខែកញ្ញា ឆ្នាំ២០២២ ស្ថានភាពរុក្ខជាតិក្នុងប្រទេសកម្ពុជានៅតែមានស្ថានភាពល្អប្រសើរ ដោយសារតែមានទឹកភ្លៀងគ្រប់គ្រាន់ក្នុងរយៈពេល៣ខែចុងក្រោយ។ នៅទូទាំងប្រទេសមានស្ថានភាពរុក្ខជាតិល្អជាងធម្មតា (ផែនទីខាងស្តាំ)។ ប៉ុន្តែ ភ្លៀងធ្លាក់ច្រើនហួសប្រមាណបានបង្កឲ្យមានទឹកជំនន់ទឹកភ្លៀង ដែលប៉ះពាល់ដល់រុក្ខជាតិនៅផ្នែកខ្លះនៃខេត្តជុំវិញបឹងទន្លេសាប (ឧ. ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ និងខេត្តសៀមរាប)។ យោងតាមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ចាប់ពីថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ទឹកជំនន់បានបង្កផលប៉ះពាល់ដល់ផ្ទៃដីដាំដុះដំណាំកសិកម្មចំនួនប្រមាណ ១៥២.៤០០ ហិកតា។

ផ្អែកតាមក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) គិតត្រឹមថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២ ផ្ទៃដីដាំដុះស្រូវរដូវវស្សាសម្រេចបាន ២,៦លាន ហិកតា ១០២,៥% នៃផែនការប្រចាំឆ្នាំ។ ការប្រមូលផលស្រូវរដូវវស្សាបានចាប់ផ្តើមហើយក្នុងបណ្តាខេត្តមួយចំនួន ហើយគិតត្រឹមខែសីហា ឆ្នាំ២០២២ ទិន្នផលទទួលបានចំនួន ១,៨៦ លានតោន។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI) ក្នុងខែកញ្ញា ឆ្នាំ២០២២**




*ប្រភព៖ FAO Global Information and Early Warning System.*

*ចំណាំ៖ ការបកស្រាយពីស្ថានភាពរុក្ខជាតិមានកម្រិតសម្រាប់តំបន់គ្របដណ្តប់ដោយពពកឬមិនមានទន្និន័យ*

# ពាណិជ្ជកម្ម

**ស្ថិតិសរុបនៃពាណិជ្ជកម្មនៅតែបង្ហាញវឌ្ឍនភាពជាវិជ្ជមាន។** ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានតម្លៃ ១៧,២៦ ពាន់លានដុល្លារ ក្នុងរយៈពេលប្រាំបួនខែដំបូងឆ្នាំ២០២២ ដែលខ្ពស់ជាងរយៈពេលដដែលកាលពីឆ្នាំមុនប្រមាណ ២២,១%។ ការនាំចេញអង្ករមានចំនួន ៩៩៩.៣២៥ តោន (មានតម្លៃស្មើ ២៨៦,៩លានដុល្លារ) ក្នុងរយៈពេលប្រាំបួនខែដំបូងឆ្នាំ២០២២ បានកើនឡើង ១០% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំមុន។ បន្ថែមលើការនាំចេញអង្ករ ការនាំចេញស្រូវមានចំនួន ២,៣៦ លាន តោន (មានតម្លៃ ៥៦៣,៥៤ លានដុល្លារ) ក្នុងរយៈពេលដូចគ្នា។ តម្លៃនាំចេញអង្ករបានធ្លាក់ចុះ ព្រោះតម្លៃអង្ករសកលកំពុងធ្លាក់ចុះ ដោយសារតែការផលិតមានចំនួនច្រើនក្នុងប្រទេសដាំដុះស្រូវ។

**កម្ពុជាបាននាំចូលជាផ្លូវការ**នូវធញ្ញជាតិសរុបចំនួន ៩៨,០ លាន ដុល្លារ (-៣០,៨% ធៀបឆ្នាំមុន) សាច់ និងសំណល់សាច់ (គ្រឿងក្នុង) ដែលអាចបរិភោគបានចំនួន ៩៧,៨ លានដុល្លារ (+១២៥,៧% ធៀបឆ្នាំមុន) បន្លែដែលអាចបរិភោគបាន និងឫស/មើមចំនួន៥,៨លានដុល្លារ (+៥,២% ធៀបឆ្នាំមុន) និងខ្លាញ់សត្វ ប្រេងរុក្ខជាតិចំនួន ១៧,០ លាន ដុល្លារ (+១២,២%) ក្នុងរយៈពេលប្រាំបួនខែដំបូងឆ្នាំ២០២២។

**ឆ្លើយតបទៅនឹងផលប៉ះពាល់ផ្ទួននៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន** និងបញ្ហាខ្សែច្រវាក់ផ្គត់ផ្គង់សកលកំពុងបន្តដែលបណ្តាលមកពីកូវីដ-១៩ នៅលើសកលលោក ប្រទេសមួយចំនួនបានធ្វើការហាមឃាត់/រិតត្បិតការនាំចេញស្បៀងអាហារ។ គិតត្រឹមដើមខែតុលា ឆ្នាំ២០២២ ប្រទេសចំនួន១៨ បានហាមឃាត់ការនាំចេញស្បៀងអាហារចំនួន២៥ ហើយប្រទេសចំនួន៥ បានអនុវត្តវិធានការរិតត្បិតចំនួន៦។ បន្ថែមលើក្តីបារម្ភពីការផ្គត់ផ្គង់នានា គិតត្រឹមដើមខែតុលា ឆ្នាំ២០២២ផងដែរ ប្រទេសមួយចំនួន ដូចជាប្រទេសចិន រុស្ស៊ី អ៊ុយក្រែន និងវៀតណាម បានអនុវត្តវិធានការរិតត្បិតការនាំចេញ ឬរិតបន្តឹងការផ្តល់អាជ្ញាប័ណ្ណនាំចេញជីរបស់ខ្លួន ដើម្បីធានាការប្រើប្រាស់ជីនៅក្នុងស្រុករបស់ពួកគេ។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ

### គិតត្រឹមខែកញ្ញា ឆ្នាំ២០២២




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២២*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជាតិជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ រដ្ឋាភិបាលបានសម្រេចបន្តអនុវត្តកម្មវិធីរហូតដល់ចុងខែកញ្ញា ឆ្នាំ២០២២។ គ្រួសារក្រីក្រប្រមាណ ៦៩១.៧០៩ គ្រួសារ (ប្រមាណ ២,៧៣ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ៨០៥,៧០៧ លានដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២។ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ រដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីប្រកាសពីដំណើរការនៃការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា ដែលមានក្រសួងផែនការជាអ្នកកំណត់អត្តសញ្ញាណគ្រួសារដែលងាយរងគ្រោះនៅទូទាំងប្រទេសមុនពេលចាប់ផ្តើមកម្មវិធី។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋសភាជាតិរបស់ប្រទេសកូរ៉េរួចរាល់ ហើយកាលពីចុងខែកញ្ញានេះ ហើយរំពឹងថានឹងអាចជម្រុញពាណិជ្ជកម្មនិងការវិនិយោគរវាងប្រទេសទាំងពីរ។ ម្យ៉ាងទៀត ប្រទេសទាំងពីរបានព្រមព្រៀងគ្នាក្នុងការស្វែងរកលទ្ធភាពផ្ទេរបច្ចេកវិទ្យានិងគៀងគរធនធាន ពីប្រទេសកូរ៉េ ដើម្បីលើកស្ទួយវិស័យស្បៀងអាហារ និងប្រែក្លាយកម្ពុជាឲ្យទៅជាមជ្ឈមណ្ឌលស្បៀងអាហារសម្រាប់អាស៊ាន។

រដ្ឋាភិបាលកម្ពុជាបានផ្តល់ជំនួយជាអង្ករចំនួន ៦.០០០ តោន ដល់រដ្ឋាភិបាល និងពលរដ្ឋគុយបា។

រដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ បានចេញអនុក្រិតស្តីពីការកែប្រែកម្រិតនៃការកំណត់ពន្ធលើប្រាក់បៀវត្សរ៍ ពី ១,៣ លាន រៀល ទៅ ១,៥ លាន រៀល ចាប់ពីខែមករា ឆ្នាំ២០២៣នេះតទៅ។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាមក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០២២ ពលរដ្ឋអាយុលើសពី៣ឆ្នាំ ជាង ១៥,២ លាននាក់ (៥០,៥% ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ យ៉ាងតិចដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិ ១០៣,៨% (៩៤,៩៧% នៃប្រជាជនសរុប)។



*ប្រភព៖ ទំព័រហ្វេសប៊ុកផ្លូវការរបស់គាំពារសង្គមកម្ពុជា ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២*

**ការចាក់វ៉ាក់សាំងកូវីដ-១៩**




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២២*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្ដើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្ដាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្ដុះបណ្ដាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្ដង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្ដប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្ដាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្ដាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្ដាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្ដប់ដល់ ៥៦ ផ្សារ។

**ការិយាល័យទីផ្សារកសិកម្ម**
នាយកដ្ឋានផែនការនិងស្ថិតិ,
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ**
ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះនៅក្នុងការិយាល័យប្រចាំប្រទេសកម្ពុជា
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,097 | → -0.9% | → -1.1% | → 0.0% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 10,618 | → 2.6% | ↑ 9.1% | ↓ -5.1% |
| ២.២ ត្រីប្រា(រស់) | Kg | 6,915 | → 3.1% | → 4.4% | → 2.3% |
| ២.៣ ត្រីអណ្ដែង(រស់) | Kg | 8,287 | → -3.7% | → 0.4% | → 3.7% |
| ២.៤ ត្រីផ្ទក់ងៀត | Kg | 25,223 | → -1.0% | → 3.1% | → -2.4% |
| ២.៥ ប្រហុក | Kg | 10,649 | → -3.9% | • | • |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 18,831 | → -3.1% | ↓ -6.4% | ↓ -9.6% |
| ៣.២ សាច់គោឃារ | Kg | 20,785 | → 2.7% | • | • |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 12,714 | → 0.4% | • | • |
| ៤.១ ស៊ុតទា | 10 eggs | 5,849 | → -3.9% | → -1.1% | ↑ 14.7% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 7,221 | → -2.7% | → -1.5% | ↑ 10.8% |
| ៥.១ ប្រេងឆា | 5 litres | 32,354 | → -2.2% | ↓ -8.6% | ↑ 20.4% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,244 | → 0.6% | → 4.3% | → 0.9% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,249 | ↑ 7.5% | • | • |
| ៧.១ សណ្ដែកដី* | Kg | 9,567 | ↑ 5.5% | ↑ 11.7% | → -1.0% |
| ៧.២ សណ្ដែកសៀង | Kg | 5,495 | ↓ -5.5% | • | • |
| ៧.៣ សណ្ដែកខៀវ | Kg | 5,938 | → -1.0% | • | • |
| ៨.១ ត្រកួន | Kg | 3,147 | ↓ -7.8% | ↑ 11.7% | ↑ 28.9% |
| ៨.២ ការ៉ុត* | Kg | 3,642 | → 1.9% | ↓ -10.8% | ↑ 9.9% |
| ៨.៣ ស្លឹកបាស* | Kg | 4,298 | ↓ -6.9% | ↓ -18.6% | ↓ -6.3% |
| ៨.៤ ស្លឹកម្រុំ* | Kg | 3,413 | ↓ -35.0% | ↓ -38.1% | ↓ -22.9% |
| ៨.៥ ស្ពៃក្រញាញ់* | Kg | 4,734 | ↓ -6.8% | ↑ 5.8% | ↑ 9.1% |
| ៨.៦ ស្ពៃតឿ* | Kg | 4,600 | → 3.9% | ↑ 8.3% | → 0.8% |
| ៨.៧ ស្ពៃចង្កឹះ | Kg | 3,914 | → -3.9% | ↑ 10.9% | ↑ 10.5% |
| ៨.៨ ស្ពៃខៀវ* | Kg | 3,958 | → -2.3% | → 4.8% | ↑ 5.9% |
| ៨.៩ ផ្ទីដូង* | Kg | 4,494 | → 1.0% | ↑ 7.8% | ↑ 47.8% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 4,376 | ↓ -30.9% | ↓ -26.8% | ↓ -15.2% |
| ៨.១១ ត្រយលម្ពៅ* | Kg | 4,444 | ↓ -20.6% | ↓ -19.5% | ↑ 9.8% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,756 | ↑ 6.2% | ↑ 10.6% | ↓ -11.3% |
| ៨.១៣ ឃ្លោក* | Kg | 2,827 | → 4.4% | ↑ 64.9% | ↑ 41.3% |
| ៨.១៤ ត្រឡាច | Kg | 2,768 | → -1.1% | ↑ 6.4% | ↑ 24.9% |
| ៨.១៥ ត្រប់វែង | Kg | 3,389 | → 4.0% | ↑ 6.8% | ↑ 23.7% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,207 | ↑ 5.8% | → 1.5% | ↑ 10.4% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 5,161 | → 4.0% | ↑ 46.3% | ↑ 40.8% |
| ៨.១៨ ននោងមូល | Kg | 3,393 | → 3.6% | ↑ 12.6% | ↑ 38.9% |
| ៨.១៩ ននោងជ្រុង* | Kg | 3,479 | ↑ 6.1% | ↑ 10.2% | ↑ 35.9% |
| ៨.២០ ល្ពងខ្ញី* | Kg | 1,473 | → -1.1% | → -4.6% | ↑ 5.8% |
| ៨.២១ សណ្ដែកគួរ | Kg | 3,936 | → -2.7% | ↓ -22.3% | ↑ 31.9% |
| ៨.២២ ត្រយូងចេក* | Kg | 2,178 | → 3.7% | ↓ -11.2% | ↓ -9.1% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 9,176 | ↑ 9.7% | ↑ 23.7% | ↑ 30.0% |
| ៨.២៤ ដើមខាត់ណា* | Kg | 6,312 | ↓ -5.9% | ↑ 30.2% | ↑ 24.9% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,580 | → 3.1% | ↑ 14.1% | ↑ 10.8% |
| ៨.២៦ ខ្ទឹមសរ | Kg | 5,513 | → 4.8% | • | • |
| ៨.២៧ អំពិលទុំ | Kg | 4,467 | ↑ 5.5% | • | • |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,186 | → -2.8% | • | • |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 3,500 | ↓ -30.0% | • | • |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,851 | ↓ -10.1% | • | • |
| ១១.១ កូកាកូឡា | 330 ml | 1,976 | → -0.1% | • | • |
| ៧.១ សាំងធម្មតា | litre | 4,642 | → -1.9% | • | • |
| ៧.២ ម៉ាស៊ូត | litre | 5,162 | → 2.4% | • | • |
| ៨.១ ជី៖ អ៊ុយរ៉េ | Kg | 3,715 | → 0.0% | • | • |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្ដែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្ដល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- • គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 1,931 | → 0.8% | → -1.5% | → -1.7% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 9,505 | → 2.7% | ↑ 8.6% | ↓ -6.5% |
| ២.២ ត្រីប្រា(រស់) | Kg | 6,100 | → 4.9% | ↑ 5.6% | → 2.0% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 7,331 | → -4.4% | → -1.9% | → 1.3% |
| ២.៤ ត្រីផ្ទក់ងៀត | Kg | 23,324 | → -0.7% | → 3.7% | → -2.3% |
| ២.៥ ប្រហុក | Kg | 9,173 | → 2.5% | • | • |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 17,325 | → -2.4% | ↓ -6.3% | ↓ -10.5% |
| ៣.២ សាច់គោឃាវ | Kg | 18,760 | → 4.0% | • | • |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 10,809 | → 0.5% | • | • |
| ៤.១ ស៊ុតទា | 10 eggs | 5,375 | → -4.8% | → -2.7% | ↑ 14.8% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,651 | → -0.6% | → -1.9% | ↑ 10.0% |
| ៥.១ ប្រេងឆា | 5 litres | 31,151 | → -1.9% | ↓ -7.5% | ↑ 18.1% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 994 | → -1.5% | → 0.1% | → -1.2% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 2,850 | ↑ 11.6% | • | • |
| ៧.១ សណ្តែកដី* | Kg | 8,768 | ↑ 6.9% | ↑ 10.9% | → -4.0% |
| ៧.២ សណ្តែកសៀង | Kg | 5,066 | ↓ -6.7% | • | • |
| ៧.៣ សណ្តែកខៀវ | Kg | 5,377 | → -0.7% | • | • |
| ៨.១ ត្រកួន | Kg | 2,567 | ↓ -10.0% | ↑ 11.1% | ↑ 26.1% |
| ៨.២ ការ៉ុត* | Kg | 3,008 | → 1.6% | ↓ -11.8% | ↑ 11.3% |
| ៨.៣ ស្លឹកបាស* | Kg | 3,348 | ↓ -8.5% | ↓ -18.8% | ↓ -6.1% |
| ៨.៤ ស្លឹកម្រុំ* | Kg | 2,708 | ↓ -33.6% | ↓ -40.9% | ↓ -27.8% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 4,005 | ↓ -7.9% | ↑ 6.9% | ↑ 9.0% |
| ៨.៦ ម្ទេសតឿ* | Kg | 3,844 | → 3.0% | ↑ 7.9% | → 1.9% |
| ៨.៧ ម្ទេសចង្កឹះ | Kg | 3,147 | ↓ -6.9% | ↑ 8.1% | ↑ 6.9% |
| ៨.៨ ម្ទេសខៀវ* | Kg | 3,151 | ↓ -5.8% | → 1.9% | → 1.5% |
| ៨.៩ ផ្ទីដូង* | Kg | 3,537 | → -1.0% | ↑ 7.5% | ↑ 42.4% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 3,600 | ↓ -28.7% | ↓ -27.9% | ↓ -17.1% |
| ៨.១១ ត្រយូងល្ពៅ* | Kg | 3,552 | ↓ -23.5% | ↓ -24.0% | → 1.8% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,175 | ↑ 6.2% | ↑ 12.0% | ↓ -13.9% |
| ៨.១៣ ឃ្លោក* | Kg | 2,229 | ↑ 10.1% | ↑ 64.6% | ↑ 30.0% |
| ៨.១៤ ត្រឡាច | Kg | 2,218 | → 1.0% | ↑ 6.9% | ↑ 25.8% |
| ៨.១៥ ត្រប់វែង | Kg | 2,750 | → 1.9% | ↑ 7.4% | ↑ 21.3% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 2,580 | ↑ 7.1% | → 2.3% | ↑ 8.9% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 4,449 | → 4.3% | ↑ 55.5% | ↑ 49.2% |
| ៨.១៨ននោងមូល | Kg | 2,726 | → 3.4% | ↑ 12.4% | ↑ 38.7% |
| ៨.១៩ ននោងជ្រុង* | Kg | 2,841 | → 5.0% | ↑ 15.1% | ↑ 35.8% |
| ៨.២០ ល្ហុងខ្ចី* | Kg | 1,076 | ↓ -5.5% | ↓ -7.0% | → 0.0% |
| ៨.២១ សណ្តែកគួរ | Kg | 3,204 | → -5.0% | ↓ -25.4% | ↑ 33.4% |
| ៨.២២ ត្រយូងចេក* | Kg | 1,729 | → -0.6% | ↓ -14.2% | ↓ -11.9% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 8,141 | ↑ 10.9% | ↑ 26.3% | ↑ 32.5% |
| ៨.២៤ ដើមខាត់ណា* | Kg | 5,467 | ↓ -7.2% | ↑ 33.0% | ↑ 26.5% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,055 | → 5.0% | ↑ 14.3% | ↑ 8.5% |
| ៨.២៦ ខ្ទឹមសរ | Kg | 4,780 | → 4.6% | • | • |
| ៨.២៧ អំពិលទុំ | Kg | 3,803 | → 4.2% | • | • |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,700 | ↓ -5.0% | • | • |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 2,833 | ↓ -33.3% | • | • |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,574 | ↓ -10.1% | • | • |
| ១១.១ កូកាកូឡា | 330 ml | 1,620 | → -2.9% | • | • |
| ៧.១ សាំងធម្មតា | litre | 4,512 | → -3.2% | • | • |
| ៧.២ ម៉ាស៊ូត | litre | 5,078 | → 2.1% | • | • |
| ៨.១ ជី៖ អ៊ុយរ៉េ | Kg | 3,263 | → 1.9% | • | • |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- • គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤

ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)

iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឲ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.1 | 26,338 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 10.6 | 29,398 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 18.8 | 23,316 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 9.4 | 3,372 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 7.1 | 2,775 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.1 | 22,180 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.6 | 1,539 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **108,918** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឲ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ <u>មិនដូចគ្នា</u> ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*

*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*

*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*

*[4] បច្ចុប្បន្នភាពទីផ្សារ ខែកញ្ញា ឆ្នាំ២០២២ WFP ប្រចាំប្រទេសកម្ពុជា។*